ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Feb-2015, 15:30
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្ដារនៃការដាក់ឯកសារ**

សំណុំរឿងលេខ : ០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ : អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់ : ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥
ភាគីអ្នកដាក់ : សហព្រះរាជអាជ្ញា
ភាសាដើម : អង់គ្លេស

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្ដីជំទាស់ និងខឹបនិយរបស់សហព្រះរាជអាជ្ញា ទៅនឹងបញ្ជីឯកសារដែល ស្នើដោយភាគី ក្នុងការឆ្លើយតបទៅនឹងអនុស្សរណៈលេខ E327 របស់អង្គជំនុំជម្រះសាលាដំបូង និង សំណើសុំឲ្យទទួលយកឯកសារ**

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្ដារា

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្ដីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោកស្រី ទូច វរល័ក្ស
លោក Calvin SAUNDERS

## I. សេចក្តីផ្តើម

1. អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ដល់គីនានាថា បើមានសេចក្តីជំទាស់ទៅនឹងឯកសារនានា ដែលបានស្នើដោយភាគីដទៃ ឲ្យដាក់ជាលាយលក្ខណ៍អក្សរ ដើម្បីទទួលយកក្នុងសវនាការ លើសំណុំរឿង 00២/0២[1]។

2. ក្នុងការឆ្លើយតបទៅនឹងសេចក្តីបង្គាប់នេះ សហព្រះរាជអាជ្ញា៖ (ក) សូមដាក់ជូននូវសេចក្តីជំទាស់របស់ខ្លួនទៅនឹងឯកសារចំនួនពីរ(0២) ដែលបានស្នើដោយមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ដោយអនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង, (ខ) បម្រុងទុកលក្ខខណ្ឌនានាសម្រាប់គោលជំហររបស់ខ្លួនទាក់ទងនឹងឯកសារចំនួនប្រាំ(0៥) ដែលបានស្នើដោយក្រុមមេធាវីការពារក្តី ដែលបច្ចុប្បន្ននេះមានតែជាភាសាអាល្លឺម៉ង់ ឬភាសាចិនតែប៉ុណ្ណោះ រហូតទាល់តែមានការបកប្រែឯកសារទាំងនោះឲ្យទៅជាភាសាមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក, (គ) ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការស្វែងរកដើម្បីឲ្យបានទទួលឯកសារមួយពីអ្នកនិពន្ធនានា ដែលបានបោះពុម្ពផ្សាយ ដែលការដកស្រង់នានានៃឯកសារនោះត្រូវបានស្នើដោយមេធាវីការពារក្តី នួន ជា, និង (ឃ) មិនជំទាស់ទៅនឹងការទទួលយកឯកសារដទៃទៀត ដែលបានស្នើដោយភាគីផ្សេងៗទេ។

## II. សេចក្តីជំទាស់

3. សហព្រះរាជអាជ្ញា សូមជំទាស់ទៅនឹងខ្សែវីឌីអូមួយ (និងប្រតិចារឹករបស់វា) ដែលបានស្នើដោយមេធាវីការពារក្តី នួន ជា[2] និងមេធាវីការពារក្តី ខៀវ សំផន[3] **(E305/12.38R, E305/12.32R** និង

---

[1] **E327** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី "ការកំណត់កាលបរិច្ឆេទសម្រាប់សេចក្តីជំទាស់ទៅនឹងឯកសារផ្សេងៗទាក់ទងនឹងសំណុំរឿង00២/0២", ១១ ធ្នូ ២០១៤។

[2] ខ្សែវីឌីអូ **E305/12.38R** សុន្ទរកថាថ្លែងដោយលោកស្រីចៅក្រម Judge Cartwright នៅឯសិក្ខាសាលា ស្តីពី៖ "ការជំនុំជម្រះអំពើក្រិដ្ឋកម្មសាហាវឃោរឃៅ៖ សាលាក្តីខ្មែរក្រហម, យុត្តិធម៌អន្តរកាល, និង នីតិរដ្ឋ" ដូចបានចុះនៅក្នុង **E307/5.2** បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង00២/0២ - ក្រុមមេធាវីការពារក្តី នួន ជា, ត្រង់លេខ ២១។

[3] ឯកសារ **E305/12.32** (ប្រតិចារឹក) និងខ្សែវីឌីអូ **E305/12.38R** ក្រោមចំណងជើងថា៖ "*ការជំនុំជម្រះអំពើក្រិដ្ឋកម្ម សាហាវឃោរឃៅ៖ សាលាក្តីខ្មែរក្រហម, យុត្តិធម៌អន្តរកាល, និង នីតិរដ្ឋ*", ១១ កក្កដា ២០១៣, ដូចបានចុះនៅក្នុង **E305/12.5**

**E305/12.32)**។ មេធាវីការពារក្តីបានស្វែករកធ្វើយុត្តិកម្មលើភាពពាក់ព័ន្ធនៃខ្សែវីឌីអូនេះ ដោយលើកឡើងថា លោកស្រីចៅក្រម Cartwright បាននិយាយអំពីការពិបាកចំពោះសហការីជាតិរបស់គាត់មួយចំនួននៅអង្គជំនុំជម្រះសាលាដំបូង ដែលបានអង្គុយនៅក្នុងសវនាការ ដោយសារពួកគាត់ធ្លាប់បានរស់នៅឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ និងធ្លាប់បានទទួលបទពិសោធន៍ពីពលកម្មកុមារ ភាពអត់ឃ្លាន ឬ អាពាហ៍ពិពាហ៍ដោយបង្ខំ។ ខ្សែវីឌីអូនេះ ពុំមានភាពពាក់ព័ន្ធ ក្នុងការកំណត់រកពីការពិតនៃបទចោទនានាទេ។ មេធាវីការពារក្តី នួន ជា បានដាក់ជូនប្រតិចារឹក នៃខ្សែវីឌីអូនេះជាផ្នែកមួយនៃការប៉ុនប៉ងថ្មីរបស់ពួកគាត់ ដើម្បីធ្វើឱ្យខូចដល់គុណវុឌ្ឍិរបស់ចៅក្រមនានានៃអង្គជំនុំជម្រះសាលាដំបូង[4] ហើយដូច្នេះ ប្រតិចារឹកនេះមាននៅក្នុងសំណុំរឿងរួចហើយ។ ខ្សែវីឌីអូនេះពុំមានគុណតម្លៃជាភស្តុតាងសម្រាប់សំណុំរឿង00២/0២ទេ ដូច្នេះហើយ វាគួរត្រូវបានបដិសេធចោល ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ។

4. សហព្រះរាជអាជ្ញា ក៏សូមជំទាស់ទៅនឹងឯកសារមួយដែលបានស្នើដោយមេធាវីការពារក្តី នួន ជា ដោយមានសេចក្តីដកស្រង់នានាចេញពីសៀវភៅរបស់ Marcel Lemonde ក្រោមចំណងជើងថា៖ "*Un juge Face aux Khmers Rouges*" ហើយដែលបានយោងជា **E189/3/1/7.1.1** រហូតដល់ និងរាប់ទាំង **E189/3/1/7.1.4**[5] ផង។ សេចក្តីដកស្រង់ទាំងនេះ គឺពុំមានគុណតម្លៃជាភស្តុតាងសម្រាប់សំណុំរឿង00២/0២ ទេ។ សម្រង់ផ្សេងៗមួយចំនួនដកចេញពីក្នុងសៀវភៅដែលនោះធ្លាប់ត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូងនេះ ដោយសារ ច្រំដែល, មិនពាក់ព័ន្ធ, មិននាំឱ្យបញ្ជាក់ការពិត ឬ មិនអាចបញ្ជាក់ជាភស្តុតាង[6]។ មេធាវីការពារក្តីមិនបានដាក់ជូននូវមូលដ្ឋាន

---

បញ្ជីឯកសារដែលបានស្នើដោយ ខៀវ សំផន សម្រាប់សំណុំរឿង00២/0២, ឧបសម្ព័ន្ធ IV.គ ក្រោមចំណងជើងថា៖ "*Liste de documents supplémentaires en lien avec les personnes proposées pour 002/02*", ត្រង់ FR 00993674។

[4] **E314/6** បណ្តឹងជំទាស់ដឹតចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន, ចៅក្រម យ៉ា សុខន, ចៅក្រម JEAN-MARC Lavergne និងចៅក្រម យូរ ឧត្តរា, កថាខណ្ឌ១២ និង កំណត់សម្គាល់ជើងទំព័រ ១១, ៩៣, ១០៦ និង ១៣៦-១៣៩។

[5] **E189/3/1/7.1.1** រហូតដល់ **E189/3/1/7.1.4**, សេចក្តីដកស្រង់ចេញពីសៀវភៅ Marcel Lemonde ក្រោមចំណងជើងថា៖ "*Un Juge Face aux Khmers Rouges*", មីនា ២០១៣, ដូចបានចុះនៅក្នុង **E307/5.2** បញ្ជីឯកសារបឋមសម្រាប់សំណុំរឿង 00២/0២ - ក្រុមមេធាវីការពារក្តី នួន ជា, ត្រង់លេខ ២១។

[6] **E280/2/1** សេចក្តីសម្រេចអង្គជំនុំជម្រះសាលាដំបូងលើសំណើសុំលើកទីពីររបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សុំឱ្យទទួលយកអត្ថបទដកស្រង់ចេញពីសៀវភៅរបស់អតីតសហចៅក្រមស៊ើបអង្កេត LEMONDE (ឯកសារ E280/2), កថាខណ្ឌ ៧-១៩ (ត្រង់កថាខណ្ឌ ១៦-១៩ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចលើសេចក្តីដកស្រង់ដែលបានស្នើ

ណាមួយ សម្រាប់ជាការពិចារណាឡើងវិញលើសេចក្ដីសម្រេចនេះទេ។ នួន ជា ក៏បានពឹងផ្អែកលើសៀវភៅនេះផងដែរ នៅក្នុងសំណើសុំប្ដឹងជំទាស់ចិត្តរបស់ខ្លួននាពេលថ្មីៗនេះ[7] ដែលត្រូវបានរកឃើញថា ពុំមានមូលដ្ឋានទេ។ ដោយហេតុថាឯកសារដែល បានស្នើនេះ មិនបង្កើតបានជាផ្នែកមួយភស្តុតាងសម្រាប់អង្គសេចក្ដីទេ នោះវាគួរតែត្រូវបានបដិសេធចោល។

## III. ខបសំនីយ

5. សហព្រះរាជអាជ្ញា បម្រុងទុកលក្ខខណ្ឌសម្រាប់គោលជំហររបស់ខ្លួន ទាក់ទងនឹងឯកសារចំនួនប្រាំ(០៥) ដែលបានស្នើដោយមេធាវីការពារក្ដី ដែលបច្ចុប្បន្ននេះ នៅក្នុងសំណុំរឿងមានតែជាភាសាអាល្លឺម៉ង់ ឬភាសាចិនម៉ង់ដារិន តែប៉ុណ្ណោះ ពីព្រោះគេពុំអាចបើកចូលមើលឯកសារទាំងនេះបានទេ ថាតើឯកសារទាំងនេះត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណា ហើយជាពិសេសនោះ ថាតើឯកសារទាំងនេះពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០២ ដែរឬទេ។

6. ឯកសារពីរដែលបានស្នើដោយ ខៀវ សំផន ក្នុងឆ្នាំ២០១១ អាចរកបានតែភាសាអាល្លឺម៉ង់ប៉ុណ្ណោះ គឺឯកសារលេខ **D359/1/1.1.53**[8] និង **D359/1/1.1.28**[9]។ លើសពីនេះ សេចក្ដីសង្ខេបនៃឯកសារដែលស្នើឡើងដោយមេធាវីការពារក្ដី ខៀវ សំផន មានភាពស្រពេចស្រពិល និងមានន័យមិនច្បាស់

---

ដោយ នួន ជា ដាក់ជូនទៅ អង្គជំនុំជម្រះតុលាការកំពូល ដូចដែល ខៀវ សំផន បានដាក់បញ្ចូលដោយការយោងទៅលើសំណើដែលបានធ្វើឡើងដោយមេធាវីការពារក្ដីលើសេចក្ដីដកស្រង់ទាំងនោះ)។

[7] **E314/6** បណ្ដឹងជំទាស់ចិត្តរបស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន, ចៅក្រម យ៉ា សុខន, ចៅក្រម JEAN-MARC Lavergne និងចៅក្រម យូរ ឧត្តរា, កថាខណ្ឌ ១១។

[8] **D359/1/1.1.53**, សម្រង់ពាក់ព័ន្ធជាភាសាអាល្លឺម៉ង់ គឺមានតែនៅត្រង់ ERN 00538259, ដែលបានចុះបញ្ជីដោយ ខៀវ សំផន នៅលើឯកសារ **E305/12.2**, ឧបសម្ព័ន្ធ IV.ក មានចំណងជើងថា "*Liste actualisée des documents initialement proposés en 201* ", ត្រង់ ERN ជាភាសាបារាំង FRE ERN 00994088។

[9] **D359/1/1.1.28**, សម្រង់ពាក់ព័ន្ធជាភាសាអាល្លឺម៉ង់ គឺមានតែនៅត្រង់ ERN 00537031, ដែលបានចុះបញ្ជីដោយ ខៀវ សំផន នៅលើឯកសារ **E305/12.2**, ឧបសម្ព័ន្ធ IV.ក មានចំណងជើងថា "*Liste actualisée des documents initialement proposés en 2011*", ត្រង់ ERN ជាភាសាបារាំង FRE ERN 00994095។

លាស់ ដែលមិនអាចកំណត់បានពីភាពពាក់ព័ន្ធ សូម្បីតែលើមូលដ្ឋានការបញ្ជាក់ដំបូងក៏គ្មានដែរ ដែលថាឯកសារនោះមានតម្លៃភវនីយ និងពាក់ព័ន្ធ[10]។

7. មេធាវីការពារក្តី នួន ជា បានស្នើឯកសារមួយដែលមានតែភាសាចិន (ឯកសារ **E307/5.2.6**)[11]។ បន្ថែមទៅនឹងខថបនីយរបស់សហព្រះរាជអាជ្ញា ដោយសារកង្វះការបកប្រែទៅជាភាសាផ្លូវការណាមួយនៃភាសាទាំងបីរបស់ អ.វ.ត.ក ដោយឈរលើមូលដ្ឋាននៃសេចក្តីអធិប្បាយដែលបានផ្តល់ជូន ឃើញថាឯកសារនេះមានភាពមិនពាក់ព័ន្ធយ៉ាងច្រើនទៅនឹងអង្គហេតុទាំងឡាយ នៃសំណុំរឿង ០០២/០២នេះ[12]។

8. សហព្រះរាជអាជ្ញា ក៏សូមរក្សាសិទ្ធិជំទាស់នឹងឯកសារចំនួនពីរផ្សេងទៀត ដែលបានស្នើឡើងដោយមេធាវីការពារក្តី នួន ជា ដែលបច្ចុប្បន្នអាចរកបានតែជាភាសាអាល្លឺម៉ង់ គឺ៖ **E307/5.2.8**[13] និង **E307/5.2.9**[14]។ លើសពីនេះ ទាក់ទងឯកសារ **E307/5.2.8** ដោយផ្អែកលើសេចក្តីអធិប្បាយខ្លី ដែលបានផ្តល់ជូនដោយមេធាវីការពារក្តី វាហាក់ដូចជាមិនពាក់ព័ន្ធទៅនឹងអង្គហេតុកំពុងនិយាយនេះទេ ក្នុងសំណុំរឿង០០២/០២ វៀលែងតែបុគ្គលមួយចំនួនដែលបានចុះបញ្ជីថា ផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការ ជាពិសេស សាក្សី 2-TCW-878 និង 2-TCW-831។ សហព្រះរាជអាជ្ញា

---

[10] សេចក្តីអធិប្បាយជាភាសាបារាំង មានដូចតទៅ៖ “*Le Comité Central en 1977 ne s’était toujours pas réuni*”, ដែលអាចបកប្រែថា “គណៈកម្មាធិការមជ្ឈិម ក្នុងឆ្នាំ១៩៧៧ មិនទាន់បានជួបគ្នានៅឡើយទេ” »។

[11] **E307/5.2.6**, សម្រង់ពីអត្ថបទមួយដោយ Weng Ming ដែលមានចំណងជើងថា “Hongse Gaomian de Xingshuai Chenfu”, 2000, ដែលបានចុះបញ្ជីដោយ នួន ជា ក្នុងឯកសារ **E307/5.2** បញ្ជីឈ្មោះឯកសារបឋមរបស់ នួន ជា សម្រាប់សំណុំរឿង០០២/០២ ត្រង់លេខ៦។

[12] ឯកសារនេះហាក់ដូចជាមានការផ្តោតជាសំខាន់ទៅលើការចុះចូលរបស់ ហ៊ុន សែន ជាមួយវៀតណាម និងប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់។

[13] **E307/5.2.8** កម្រងប្រវត្តិរូបសង្ខេបខ្លីចំនួន២១ (“kurzbiographies”) ដែលបានផលិតដោយក្រសួងសន្តិសុខរដ្ឋនៃសាធារណៈរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (german Democratic Republic Ministry of State Security) (Stasi), ដូចបានចុះបញ្ជីក្នុងឯកសារលេខ **E307/5.2** បញ្ជីឈ្មោះឯកសារបឋមរបស់ នួន ជា សម្រាប់សំណុំរឿង០០២/០២ ត្រង់លេខ៨។

[14] **E307/5.2.9**, របាយការណ៍ចារកម្មចោះៗ ដែលបានផលិតដោយក្រសួងសន្តិសុខរដ្ឋនៃសាធារណៈរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ (german Democratic Republic Ministry of State Security) (Stasi), ដូចបានចុះបញ្ជីក្នុងឯកសារលេខ **E307/5.2** បញ្ជីឈ្មោះឯកសារបឋមរបស់ នួន ជា សម្រាប់សំណុំរឿង០០២/០២ ត្រង់លេខ៩។

ជាតិនៅតែប្រកាន់ជំហរចំពោះការជំទាស់របស់លោកស្រីដដែល ទាក់ទងនឹងសក្ខីកម្មដែលបានស្នើឡើងរបស់សាក្សីទាំងពីរនាក់នេះ[15]។

## IV. សំណើ

9. សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងទាក់ទងបុគ្គលដែលមានឈ្មោះ Messrs De Nike, Quigley និង Robinson ដែលជាអ្នកនិពន្ធសៀវភៅមានចំណងជើងថា *"អំពើប្រល័យពូជសាសន៍នៅកម្ពុជា: ឯកសារពីការជំនុំជម្រះក្តី ប៉ុល ពត និង អៀង សារី"*, សាកលវិទ្យាល័យសារព័ត៌មាន Pennsylvania (University of Pennsylvania Press), ដើម្បីទទួលបានឯកសារមួយដែលសម្រង់នៃឯកសារនេះ ត្រូវបានស្នើឱ្យទទួលយកក្នុងសំណុំរឿង០០២/០២ ដោយមេធាវីការពារក្តី នួន ជា (ឯកសារ **E307/5.2.12**)[16]។ សម្រង់ដែលពាក់ព័ន្ធនោះ គឺកំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍គណៈកម្មាធិការមជ្ឈិមបក្ស ចុះថ្ងៃទី១១ មេសា ១៩៧៧។ កំណត់ហេតុនៃកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ទាំងនេះ ដាក់ឈ្មោះអ្នកដែលចូលរួមក្នុងកិច្ចប្រជុំ[17] ហើយមានសេចក្តីណែនាំដូចតទៅ៖ "គ្រប់អង្គភាព សេវាកម្ម និងក្រសួងទាំងអស់ ត្រូវចេះមានគំនិតផ្តួចផ្តើមក្នុងអង្គភាពរបស់ខ្លួន ដើម្បីបន្តសំរិតសំរាំង និងបោសសម្អាតខ្មាំង ហើយក្នុងពេលជាមួយគ្នានេះ ក៏ត្រូវចេះអនុវត្តសកម្មភាពជាធម្មតា"។ សហព្រះរាជអាជ្ញាយល់ស្របតាមមេធាវីការពារក្តី នួន ជា ដែលថា ឯកសារនេះគួរត្រូវបានទទួលយកជាភ័ស្តុតាងក្នុងសំណុំរឿង០០២/០២ ដោយសារវាពាក់ព័ន្ធនឹងតួនាទីរបស់ជនជាប់ចោទ និងគោលនយោបាយរបស់ បកក ចំពោះអ្នកដែលគេចាត់ទុកថាខ្មាំង។ ជាការបន្ថែម សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង

---

[15] សូមមើល ការជំទាស់របស់សហព្រះរាជអាជ្ញាជាតិទៅនឹងសាក្សី និងអ្នកជំនាញ ដែលបានស្នើឡើងដោយភាគីដទៃ, ៣០ ឧសភា ២០១៤។

[16] **E307/5.2.12** សម្រង់ពីកំណត់ហេតុប្រជុំ ចុះថ្ងៃទី១១ មេសា ១៩៧៧, កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស នៅក្នុងសៀវភៅរបស់ De Nike, Quigley & Robinson (ច្បាប់បោះពុម្ពផ្សាយ) (2000) ។ *អំពើប្រល័យពូជសាសន៍នៅកម្ពុជា: ឯកសារពីការជំនុំជម្រះក្តី ប៉ុល ពត និង អៀង សារី" ("Genocide in Cambodia: Documents from the Trial of Pol Pot and Ieng Sary")*, សកលវិទ្យាល័យសារព័ត៌មាន Pennsylvania (University of Pennsylvania Press), កថាខណ្ឌ 385-386; 1979 ឯកសារសវនាការលេខ 2.5.06, ដូចបានចុះបញ្ជីក្នុងឯកសារ **E307/5.2** បញ្ជី ឈ្មោះឯកសារបឋមរបស់ នួន ជា សម្រាប់សំណុំរឿង០០២/០២ ត្រង់លេខ១២។

[17] ប៉ុល, នួន, ភឹម, ម៉ុក, វន, វ៉ាន់, ញឹម, កែ និង ខៀវ។

ព្យាយាមធ្វើយ៉ាងណាទទួលបានសំណៅនៃឯកសារនេះទាំងមូល។ ដោយសារកំណត់ហេតុនៃកិច្ចប្រជុំដទៃទៀតរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងសំណុំរឿង គឺចុះកាលបរិច្ឆេទឆ្នាំ១៩៧៥ ឬ ១៩៧៦ មានន័យថាវាជាឯកសារសំខាន់បំផុតតែមួយគត់ ដែលឆ្លុះបញ្ចាំងពីសេចក្តីសម្រេចសំខាន់ៗ ដែលបានធ្វើឡើងដោយគណៈកម្មាធិការនេះ នៅក្នុងចិរវេលាមួយដែលការបោសសម្អាតផ្ទៃក្នុងត្រូវបានចាប់ផ្តើមធ្វើឡើងជាទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

## V. សេចក្តីសន្និដ្ឋាន

10. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះសាលាដំបូង៖

(ក) ច្រានចោលឯកសារលេខ **E305/12.38R** (ដែលបានលើកយោងថា E305/12.32R និង ប្រតិចារឹក E305/12.32) និងឯកសារ **E189/3/1/7.1.1** រហូតដល់ និងរួមទាំងឯកសារ **E189/3/1/7.1.4**។

(ខ) ពន្យារសេចក្តីសម្រេចរបស់ខ្លួនលើឯកសារដែលអាចរកបានតែភាសាចិន ឬអាល្លឺម៉ង់ ដូចបានលើកយោងក្នុងកថាខណ្ឌ៦ ដល់៨; និង

(គ) ទាក់ទងបុគ្គល Messrs De Nike, Quigley និង Robinson ដើម្បីទទួលបានឯកសារ **E307/5.2.12** ទាំងមូល៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |